# PNN PLUS – PRIVACY & POLICY

| English | Khmer |
|---|---|
| **<u>PNN PLUS Privacy & Policy</u>**<br><br>PNN PLUS prioritizes the protection of the privacy and security of our site visitors, including you. We know and fully understand and respect the importance of data privacy and security on the Internet. We expect you are informed and secured when it comes to our handling and usage of your information. This notice therefore explains:<br><br>● what information we collect when you're using PNN PLUS app, or when you're communicating with us;<br>● why we collect that information<br>● how we may then use that information<br>● how we share that information<br>● how long we keep your information, and how we protect it whilst we have it<br>● what we won't do with your information<br>● what choice and options you have to control your information<br>● how users can request data deletion?<br><br>So, you only need to look in one place to find out all you need to know, this notice covers all PNN PLUS's app and service. Because we're an online service, | <u>លក្ខខណ្ឌឯកជនភាព និងគោលការណ៍</u><br><br>PNN PLUS ផ្តល់អាទិភាពចំពោះការការពារឯកជនភាព និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ទូទៅដែលបាននិងកំពុងប្រើប្រាស់កម្មវិធី និងសេវាកម្មរបស់យើងខ្ញុំ រួមទាំងអ្នកផងដែរ។ យើងខ្ញុំដឹង និងយល់យ៉ាងពេញលេញ និងគោរពនូវសារៈសំខាន់នៃភាពឯកជន និងសុវត្ថិភាពទិន្នន័យនៅលើអ៊ីនធឺណិត។ យើងខ្ញុំរំពឹងថា លោកអ្នកនឹងទទួលការជូនដំណឹង និងធានាសុវត្ថិភាព ចំពោះការគ្រប់គ្រង និងការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់លោកអ្នក។ ខាងក្រោមជាសេចក្តីពន្យល់ថាតើយើងខ្ញុំគ្រប់គ្រងនិងប្រើប្រាស់ទិន្នន័យរបស់លោកអ្នកយ៉ាងដូចម្តេចខ្លះ៖<br><br>● តើព័ត៌មានអ្វីខ្លះដែលយើងខ្ញុំប្រមូលពីអ្នកកំពុងប្រើប្រាស់កម្មវិធី PNN PLUS ឬនៅពេលលោកអ្នកទំនាក់ទំនងជាមួយយើងខ្ញុំ?<br>● ហេតុអ្វីបានជាយើងខ្ញុំត្រូវប្រមូលព័ត៌មានពីលោកអ្នក?<br>● របៀបដែលយើងខ្ញុំអាចប្រើប្រាស់ព័ត៌មានរបស់លោកអ្នក។<br>● របៀបដែលយើងខ្ញុំចែករំលែកព័ត៌មានរបស់លោកអ្នក។<br>● រយៈពេលដែលយើងខ្ញុំរក្សាទុកព័ត៌មានរបស់លោកអ្នក និងរបៀបដែលយើងខ្ញុំការពារព័ត៌មានទាំងនោះ ខណៈពេលដែលយើងខ្ញុំកំពុងគ្រប់គ្រងព័ត៌មានទាំងនោះ។<br>● អ្វីដែលយើងខ្ញុំនឹងមិនធ្វើជាមួយព័ត៌មានរបស់លោកអ្នក។<br>● តើជម្រើស និងលក្ខខណ្ឌអ្វីខ្លះដែលលោកអ្នកត្រូវគ្រប់គ្រងព័ត៌មានរបស់លោកអ្នក។ |

| | |
|---|---|
| the wording does have to get a little technical at times. But we've done our best to try to explain things as clearly as we can. We're may not have covered every aspect perfectly though, so we're always happy to take any questions, comments, or suggestions relating to this notice. Just contact our team if you'd like to discuss this with us. | ● តើអ្នកប្រើប្រាស់អាចស្នើសុំការលុបទិន្នន័យដោយរបៀបណា?<br><br>អ្វីដែលអ្នកចាំបាច់ត្រូវដឹង៖ សេចក្តីជូនដំណឹងនេះគ្របដណ្តប់លើកម្មវិធី និងសេវាកម្មរបស់ PNN PLUS ទាំងមូល។ ដោយសារយើងជាសេវាកម្មអនឡាញ (អ៊ីនធឺណេត) ពេលខ្លះយើងមិនជៀសផុតពីការប្រើពាក្យបច្ចេកទេសមួយចំនួន។ ប៉ុន្តែយើងខ្ញុំព្យាយាមពន្យល់អ្វីៗឱ្យបានច្បាស់តាមដែលយើងខ្ញុំអាចធ្វើទៅបាន។ ប្រាកដណាស់ យើងខ្ញុំពិតជាមិនអាចគ្របដណ្តប់គ្រប់ទិដ្ឋភាពទាំងអស់យ៉ាងល្អឥតខ្ចោះនោះទេ ដូច្នេះហើយយើងខ្ញុំតែងតែរីករាយស្វាគមន៍ក្នុងការទទួលយកសំណួរ មតិយោបល់ ឬការផ្តល់យោបល់ពីលោកអ្នក។ លោកអ្នកអាចទាក់ទងក្រុមការងាររបស់យើងខ្ញុំ ប្រសិនបើអ្នកចង់ពិភាក្សាអំពីបញ្ហានេះ។ |

**Collection of Personal Information**

PNN PLUS would like to make you aware that personal information collected online could be disclosed within our company and to third parties for the purposes of marketing and direct sales. When you register a PNN PLUS app account, the personal information we collect may include your:

- Username
- Phone number
- Email Address
- Date of Birth (Optional)
- Gender (Optional)
- Location (country/city)

The mandatory personal information we collect from you will be used and or shared within our corporate group and with third parties for one of the following purposes:

To allow us to administer your registered account with us
The non-mandatory personal information such as date of birth, gender, location, and IP address are used to carry out research on our users' demographics and for us to send you suggestion or information in the form of promotional emails, SMS, or App notification which we think you may find useful, thereby, enhancing your experience when you visit our app. By providing us this non-mandatory personal information, you are deemed to have consented to be part of our research and to receiving suggestions or

**ការប្រមូលព័ត៌មានផ្ទាល់ខ្លួន**

PNN PLUS សូមជម្រាបជូនលោកអ្នកថា ព័ត៌មានផ្ទាល់ខ្លួនដែលប្រមូលបានតាមអនឡាញ (អ៊ីនធឺណេត) អាចត្រូវបានបង្ហាញនៅក្នុងក្រុមហ៊ុនរបស់យើងខ្ញុំ និងដល់ភាគីទីបីសម្រាប់គោលបំណងផ្សព្វផ្សាយទីផ្សារ និងការលក់ដូរដោយផ្ទាល់។
នៅពេលចុះឈ្មោះបង្កើតគណនីជាមួយកម្មវិធី PNN PLUS ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកដែលយើងខ្ញុំប្រមូលរួមមាន៖

- ឈ្មោះរបស់លោកអ្នក
- លេខទូរស័ព្ទរបស់លោកអ្នក
- អាសយដ្ឋានអ៊ីម៉ែល
- ថ្ងៃខែឆ្នាំកំណើត (ជាជម្រើស)
- ភេទ (ជាជម្រើស)
- ទីតាំង (ប្រទេស/ទីក្រុង)

| | |
|---|---|
| information as outlined above. You could also be contacted for the purposes of marketing and sales. | ព័ត៌មានផ្ទាល់ខ្លួនជាកាតព្វកិច្ច ដែលយើងប្រមូលពីលោកអ្នកនឹងត្រូវប្រើប្រាស់ និងឬចែករំលែកនៅក្នុងក្រុមសាជីវកម្មរបស់យើង និងជាមួយភាគីទីបីសម្រាប់គោលបំណងដូចខាងក្រោម៖<br><br>ដើម្បីអនុញ្ញាតឱ្យយើងគ្រប់គ្រងព័ត៌មានគណនីរបស់លោកអ្នក ដែលបានចុះឈ្មោះជាមួយយើងខ្ញុំ។<br><br>ព័ត៌មានផ្ទាល់ខ្លួនដែលមិនជាកាកព្វកិច្ច ដូចជា ថ្ងៃខែឆ្នាំកំណើត ភេទ ទីតាំង និងអាសយដ្ឋាន IP ត្រូវបានប្រើដើម្បីអនុវត្តការស្រាវជ្រាវលើប្រជាសាស្ត្ររបស់អ្នកប្រើប្រាស់ ហើយសម្រាប់យើងខ្ញុំវិញនឹងប្រើដើម្បីផ្ញើសារផ្តល់យោបល់ ឬព័ត៌មានទៅកាន់លោកអ្នកក្នុងទម្រង់ជាអ៊ីម៉ែលផ្សព្វផ្សាយ សារ SMS ឬទម្រង់ជាការជូនដំណឹង (App Notification) ដែលយើងខ្ញុំគិតថា មានសារប្រយោជន៍ចំពោះលោកអ្នក និងក្នុងន័យដើម្បីសម្រួលដល់ការប្រើប្រាស់របស់លោកអ្នក នៅពេលដែលលោកអ្នកចូលមកប្រើប្រាស់កម្មវិធីរបស់យើងខ្ញុំ។ តាមរយៈការផ្តល់ឱ្យយើងខ្ញុំនូវព័ត៌មានផ្ទាល់ខ្លួនដែលមិនជាកាតព្វកិច្ចនេះ លោកអ្នកក៏ត្រូវបានចាត់ទុកថា បានយល់ព្រមក្នុងផ្នែកនៃការស្រាវជ្រាវរបស់យើងខ្ញុំ និងដើម្បីទទួលបានការផ្តល់យោបល់ ឬព័ត៌មានដូចដែលបានរៀបរាប់ខាងលើ។ អ្នកក៏អាចនឹងត្រូវបានទាក់ទងសម្រាប់គោលបំណងផ្សព្វផ្សាយទីផ្សារ និងការលក់ផងដែរ។ |

| | |
|---|---|
| **<u>Accessing and Updating Your Personal Information</u>**<br>You can access and update your personal information anytime by accessing your account on PNN PLUS app.<br><br>There are four main types of use for your data. Here’s how and why we may use your data.<br><br>1. Site functionality – this allows you to navigate the site and use our features, such as “Watch video” and “Add to List”.<br>2. Site analytics – this allows us to measure and analyze how our users use the app, to improve both its functionality and your entertainment experience.<br>3. User preference – this allows us to remember your preferences (like your video), so we can make your experience as seamless as possible, and more personal to you.<br>4. Advertising - this allows us to deliver ads relevant to you. They also limit the number of times that you see an ad and help us measure the effectiveness of our marketing campaigns. | <u>ការគ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក</u><br>អ្នកអាចគ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកបានគ្រប់ពេល ដោយចូលទៅកាន់គណនីរបស់អ្នកនៅលើកម្មវិធី PNN PLUS ។<br><br>៤ចំណុចសំខាន់ៗនៃការប្រើប្រាស់ទិន្នន័យរបស់អ្នក។ ខាងក្រោមនេះជារបៀប និងមូលហេតុដែលយើងអាចប្រើទិន្នន័យរបស់អ្នក។ |

| | |
|---|---|
| By using our app, you agree to us placing these sorts of data on your device and accessing them when you visit the app in the future.<br>We also implement tracking methods based on Display Advertising (e.g., Google Display Network Impression Reporting, or Google Analytics Demographics and Interest Reporting) and can collect information such as age, gender, interests, and interaction with ads impressions.<br><br>PNN PLUS and third-party vendors, including Google, use first-party (such as Google Analytics) platforms to inform, optimize, and serve ads based on someone’s past visits to the app and across the Internet. | ១. សម្រាប់ការដំណើរកម្មវិធី – នេះអនុញ្ញាតឱ្យលោកអ្នកដំណើរការ និងប្រើប្រាស់មុខងារនៃកម្មវិធី ដែលមានដូចជា "មើលវីដេអូ" និង "ការដាក់បញ្ចូលក្នុងបញ្ជី"។<br>២. សម្រាប់មុខងារវិភាគរបស់កម្មវិធី – នេះអនុញ្ញាតឱ្យយើងខ្ញុំវាស់វែង និងវិភាគពីរបៀបដែលលោកអ្នកប្រើប្រាស់កម្មវិធី និងដើម្បីកែលម្អមុខងាររបស់កម្មវិធី ព្រមទាំងបទពិសោធន៍នៃការទស្សនាកម្សាន្តរបស់លោកអ្នក។<br>៣. សម្រាប់ចំណូលចិត្តរបស់អ្នកប្រើប្រាស់ – នេះអនុញ្ញាតឱ្យយើងខ្ញុំកត់ត្រាអំពីចំណូលចិត្តរបស់លោកអ្នក (ដូចជាវីដេអូដែលលោកពេញចិត្ត) ដូច្នេះយើងអាចបង្កើតបទពិសោធន៍ប្រើប្រាស់របស់លោកអ្នកឱ្យបានរលូនតាមដែលអាចធ្វើទៅបាន និងកាន់តែមានលក្ខណៈផ្ទាល់ខ្លួនសម្រាប់លោកអ្នក។<br>៤. សម្រាប់ការផ្សាយពាណិជ្ជកម្ម - នេះអនុញ្ញាតឱ្យយើងខ្ញុំចែកចាយការផ្សាយពាណិជ្ជកម្មដែលទាក់ទងនឹងអ្នក។ ការកំណត់ចំនួនដងដែលលោកអ្នកបានឃើញការផ្សាយពាណិជ្ជកម្មនីមួយៗ និងជួយវាស់ស្ទង់ប្រសិទ្ធភាពនៃយុទ្ធនាការទីផ្សាររបស់យើងខ្ញុំផងដែរ។<br><br>តាមរយៈការប្រើប្រាស់កម្មវិធីរបស់យើងខ្ញុំ លោកអ្នកយល់ព្រមឱ្យយើងខ្ញុំដាក់ប្រភេទទិន្នន័យទាំងនេះនៅលើឧបករណ៍ (ទូរសព្ទ) របស់លោកអ្នក ហើយមានសិទ្ធិប្រើប្រាស់ទិន្នន័យទាំងនេះនៅពេលអ្នកចូលមកកាន់កម្មវិធីនាពេលក្រោយៗទៀត។<br>យើងក៏អនុវត្តវិធីសាស្រ្តតាមដានដោយផ្អែកលើការបង្ហាញការផ្សាយពាណិជ្ជកម្ម (ឧ. Google Display Network Impression Reporting ឬ Google Analytics Demographics និង Interest Reporting) ហើយអាចប្រមូលព័ត៌មានដូចជាអាយុ ភេទ ចំណាប់អារម្មណ៍ និងអន្តរកម្មជាមួយចំណាប់អារម្មណ៍នៃការផ្សាយពាណិជ្ជកម្ម។ |

<table>
<tr>
<td>
<u>Security of Your Personal Information</u><br>
PNN PLUS ensures that all information collected will be safely and securely stored. We protect your personal information by:<br><br>
● Allowing access to personal information only via passwords<br>
● Maintaining technology to prevent unauthorized device access; and<br>
● Securely destroying your personal information when it is no longer needed for our record retention purposes<br><br><br><br><br><br>
● Users have two options to request to delete the account:<br><br>
First Option:<br>
To delete your account, please follow the steps below:<br>
1. Click on the following link: https://admin.pnn.com.kh/c-delete-account<br>
2. On the page that opens, you will find two fields requesting your phone number and password. Please enter the phone number and password that you used to register with PNN PLUS.<br>
3. Once you have filled in the required information, click on the "Submit" button.<br>
4. You will then receive an OTP (One-Time Password) via SMS. Please enter the OTP in the provided field.
</td>
<td>
PNN PLUS និងអ្នកលក់ភាគីទីបី រួមទាំង Google ប្រើប្រាស់ថ្នាលភាគីទីមួយ (ដូចជា Google Analytics) ដើម្បីជូនដំណឹង បង្កើនប្រសិទ្ធភាព និងបម្រើដល់ការផ្សាយពាណិជ្ជកម្ម ដោយផ្អែកលើការធ្លាប់ចូលមកប្រើប្រាស់កម្មវិធី និងនៅលើអ៊ីនធឺណេតរបស់នរណាម្នាក់ នាពេលកន្លងមក។<br><br><br><br><br><br><br><br><br><br>
<u>សុវត្ថិភាពនៃព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក</u>
</td>
</tr>
</table>

| | |
|---|---|
| 5. After completing these steps, your account will be deleted.<br><br>**Second Option (For iOS users only)**:<br>If you are an iOS user, you can delete your account through the PNN app by following these steps:<br>1. Open the app and click on the Menu Bar.<br>2. Select "View Profile" from the menu options.<br>3. On the "View Profile" screen, you will find the option to delete your account.<br>4. Follow the on-screen instructions and provide all the necessary information step by step.<br>5. Once you have completed all the required steps, the app will delete your account.<br><br>Please note that the following information has been permanently removed from our system:<br><br>1. Subscription Plan: All details regarding your current subscription plan have been deleted, and you will no longer have access to any premium features or benefits associated with it.<br><br>2. Personal Information: Any personal information provided during your account registration, such as your name, email address, and contact number, has | PNN PLUS ធានាថារាល់ព័ត៌មានដែលប្រមូលបាននឹងត្រូវបានរក្សាទុកដោយត្រឹមត្រូវ និងសុវត្ថិភាព។ យើងខ្ញុំការពារព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកតាមរយៈ៖<br><br>• អនុញ្ញាតឱ្យគ្រប់គ្រងកែប្រែព័ត៌មានផ្ទាល់ខ្លួនបានតាមរយៈ ពាក្យសម្ងាត់ ប៉ុណ្ណោះ។<br>• ការថែទាំបច្ចេកវិទ្យាដើម្បីការពារការចូលប្រើប្រាស់ឧបករណ៍ (ទូរសព្ទ) ដែលគ្មានការអនុញ្ញាត។<br>• ការបំផ្លាញ (លុបចោល) ដោយសុវត្ថិភាពនូវព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ពីប្រព័ន្ធរបស់យើងខ្ញុំនៅពេលដែលយើងខ្ញុំលែងត្រូវការព័ត៌មានទាំងនេះ។<br><br>• អ្នកប្រើប្រាស់មានជម្រើសពីរដើម្បីចាប់ផ្តើមដំណើរការលុប៖<br><br>ជម្រើសដំបូង៖<br>ដើម្បីលុបគណនីរបស់អ្នក សូមអនុវត្តតាមជំហានខាងក្រោម៖<br>1. ចុចលើ link ខាងក្រោម៖ https://admin.pnn.com.kh/c-delete-account<br>2. នៅលើទំព័រដែលបើក អ្នកនឹងត្រូវតែបំពេញលេខទូរស័ព្ទ និងពាក្យសម្ងាត់របស់អ្នក។ សូមបញ្ចូលលេខទូរស័ព្ទ និងពាក្យសម្ងាត់ដែលអ្នកធ្លាប់ចុះឈ្មោះជាមួយPNN PLUS ។<br>3. នៅពេលដែលអ្នកបានបំពេញព័ត៌មានដែលត្រូវការហើយ ចុចលើប៊ូតុង "ដាក់ស្នើ"។<br>4. បន្ទាប់មកអ្នកនឹងទទួលបាន OTP (One-Time Password) តាមរយៈសារ SMS។ សូមបញ្ចូល OTP នៅក្នុងវាលដែលបានផ្តល់។<br>5. បន្ទាប់ពីបញ្ចប់ជំហានទាំងនេះ គណនីរបស់អ្នកនឹងត្រូវបានលុប។ |

| | |
|---|---|
| been completely erased from our database.<br><br>3. Login Account: Your account credentials, including your username and password, have been deactivated and removed from our system. You will no longer be able to log in to the PNN PLUS platform using your previous account details. | ជម្រើសទីពីរ (សម្រាប់តែអ្នកប្រើប្រាស់ iOS)៖<br>ប្រសិនបើអ្នកជាអ្នកប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការ iOS អ្នកអាចលុបគណនីរបស់អ្នកតាមរយៈកម្មវិធី PNN ដោយធ្វើតាមជំហានទាំងនេះ៖<br>1. បើកកម្មវិធីហើយចុចលើ Menu Bar។<br>2. ជ្រើសរើស "មើលទម្រង់" ពីជម្រើសម៉ឺនុយ។<br>3. នៅលើអេក្រង់ "មើលប្រវត្តិរូប" អ្នកនឹងឃើញជម្រើសដើម្បីលុបគណនីរបស់អ្នក។<br>4. អនុវត្តតាមការណែនាំនៅលើអេក្រង់ ហើយផ្តល់ព័ត៌មានចាំបាច់ទាំងអស់ជាជំហានៗ។<br>5. នៅពេលដែលអ្នកបានបញ្ចប់ជំហានដែលត្រូវការទាំងអស់ កម្មវិធីនឹងលុបគណនីរបស់អ្នក។<br><br>សូមចំណាំថាព័ត៌មានខាងក្រោមត្រូវបានដកចេញជាអចិន្ត្រៃយ៍ពីប្រព័ន្ធរបស់យើង៖ |

| | |
|---|---|
| **<u>Disclosure of Personal Information</u>**<br>We will not share your information with any other organization other than our corporate group and those third parties directly related to our App. In exceptional circumstances, PNN PLUS may be required to disclose personal information, such as when there are grounds to believe that the disclosure is necessary to prevent a threat to life or health or required by the law.<br><br>If you believe that your privacy has been breached by PNN PLUS please contact us at pnnplus@pnn.com.kh or +85569568456 and we will try to resolve the issue.<br><br>This information is collected for analysis and evaluation in order to help us improve our app and the services we provide. This data will not be used in association with any other personal information. | 1. គម្រោងការជាវ៖ ព័ត៌មានលម្អិតទាំងអស់ទាក់ទងនឹងគម្រោងការជាវបច្ចុប្បន្នរបស់អ្នកត្រូវបានលុប ហើយអ្នកនឹងលែងមានសិទ្ធិចូលប្រើមុខងារពិសេស ឬអត្ថប្រយោជន៍ដែលពាក់ព័ន្ធជាមួយវាទៀតហើយ។<br><br>2. ព័ត៌មានផ្ទាល់ខ្លួន៖ ព័ត៌មានផ្ទាល់ខ្លួនណាមួយដែលបានផ្តល់ជូនក្នុងអំឡុងពេលចុះឈ្មោះគណនីរបស់អ្នក ដូចជាឈ្មោះ អាសយដ្ឋានអ៊ីមែល និងលេខទំនាក់ទំនងរបស់អ្នកត្រូវបានលុបទាំងស្រុងពីមូលដ្ឋានទិន្នន័យរបស់យើង។<br><br>3. ចូលគណនី៖ អត្តសញ្ញាណគណនីរបស់អ្នក រួមទាំងឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់របស់អ្នកត្រូវបានបិទដំណើរការ និងដកចេញពីប្រព័ន្ធរបស់យើង។ អ្នកនឹងមិនអាចចូលទៅក្នុងវេទិកា PNN PLUS ដោយប្រើព័ត៌មានលម្អិតគណនីពីមុនរបស់អ្នកទៀតទេ។ |

| | |
|---|---|
| **<u>Changes to the Privacy Policy</u>**<br>We may change this Privacy Policy from time to time. If we make significant changes in the way we treat your personal information, or to the Privacy Policy, we will make that clear on the PNN PLUS app or Services, or by some other forms of communication, so that you are able to review the changes before you continue to use PNN PLUS. However, it is your responsibility to review this policy from time to time to get yourself updated. | **<u>ការបង្ហាញព័ត៌មានផ្ទាល់ខ្លួន</u>**<br>យើងនឹងមិនចែករំលែកព័ត៌មានរបស់អ្នកជាមួយស្ថាប័នណាមួយ ក្រៅពីក្រុមសាជីវកម្មរបស់យើងខ្ញុំ និងភាគីទីបីដែលទាក់ទងដោយផ្ទាល់ទៅនឹងកម្មវិធីរបស់យើងខ្ញុំនោះទេ។ លើកលែងតែក្នុងកាលៈទេសៈពិសេសណាមួយដែល PNN PLUS អាចតម្រូវឱ្យបញ្ចេញព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ដូចជាក្នុងហេតុផលចាំបាច់ដើម្បីការពារការគំរាមកំហែងដល់អាយុជីវិត ឬសុខភាព ឬតម្រូវដោយច្បាប់។<br><br>ប្រសិនបើអ្នកជឿថា ឯកជនភាពរបស់អ្នកត្រូវបានបំពានដោយ PNN PLUS សូមទាក់ទង pnnplus@pnn.com.kh ឬ +85569568456 យើងខ្ញុំនឹងព្យាយាមដោះស្រាយបញ្ហានេះ។<br><br>ទិន្នន័យព័ត៌មានទាំងឡាយដែលត្រូវបានប្រមូលគឺក្នុងបំណងសម្រាប់ការវិភាគ និងវាយតម្លៃ ដើម្បីជួយយើងខ្ញុំកែលម្អកម្មវិធី និងសេវាកម្មដែលយើងខ្ញុំបាននិងកំពុងផ្តល់ជូន។ |

| | |
|---|---|
| | ទិន្នន័យទាំងនេះ នឹងមិនត្រូវបានប្រើប្រាស់ក្នុងបំណងបម្រើអោយកិច្ចការផ្ទាល់ខ្លួនផ្សេងទៀតឡើយ។<br><br><u>ការផ្លាស់ប្តូរចំពោះគោលការណ៍ឯកជនភាព</u><br>យើងខ្ញុំអាចនឹងផ្លាស់ប្តូរ គោលការណ៍ឯកជនភាព នេះ ទៅតាមពេលវេលានិងកាលៈទេសៈជាក់ស្តែង។ ប្រសិនបើយើងខ្ញុំធ្វើការផ្លាស់ប្តូរធាតុសំខាន់ៗនៅក្នុង គោលការណ៍ឯកជនភាព នេះ ឬ ផ្លាស់ប្តូរវិធីសាស្ត្រគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក យើងខ្ញុំនឹងធ្វើការបង្ហាញឱ្យច្បាស់លាស់នៅលើកម្មវិធី ឬសេវាកម្មរបស់ PNN PLUS ឬតាមរយៈការទំនាក់ទំនងផ្សេងទៀត ដើម្បីអនុញ្ញាតិអោយលោកអ្នកអាចបានពិនិត្យមើលលើការផ្លាស់ប្តូរ មុនពេលោកអ្នកបន្តប្រើ PNN PLUS ។ |

| | |
|---|---|
| | ទោះជាយ៉ាងណាក្តី វាជាទំនួលខុសត្រូវរបស់អ្នកក្នុងការត្រួតពិនិត្យគោលការណ៍ទាំងនេះជាប្រចាំដើម្បីធ្វើឱ្យលោកអ្នកទទួលបានបច្ចុប្បន្នភាពថ្មីៗ៕ |